ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




កសវ

# Work Activities

ប្រចាំខែធ្នូ ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមសីលធម៌គិលានុបដ្ឋាក | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង | ៣ |
| ៣- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយស្តីពីៈ<br>ក- សេចក្តីព្រាងច្បាប់ ស្តីពីផ្លូវថ្នល់<br>ខ- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ៥ |
| ៤- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយស្តីពីៈ<br>ក- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីក្រុមសីលធម៌គិលានុបដ្ឋាក<br>ខ- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង | ៦ |
| ៥- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ | ៧ |
| ៦- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ក្រមសីលធម៌គិលានុបដ្ឋាក

សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាកត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសម្តងរួចហើយកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ ក៏ប៉ុន្តែអង្គប្រជុំជំនាញបច្ចេកទេសពេលនោះបានសម្រេចឲ្យក្រសួងសុខាភិបាលរៀបចំឡើងវិញតាមទម្រង់ក្រមសីលធម៌ឆ្មប។ តាមស្មារតីនៃអង្គប្រជុំ ក្រសួងសុខាភិបាលបានរៀបចំសេចក្តីព្រាងនេះឡើងវិញ ហើយបានស្នើសុំដាក់ឆ្លងម្តងទៀតកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣។

ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ឡាំ ខា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ បានដឹកនាំកិច្ចអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិ-បាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសុខាភិបាល។



ក្រសួងសុខាភិបាលបានយកចិត្តទុកដាក់លើកកម្ពស់ការពារនិងថែទាំសុខភាពជូនប្រជាជនទាំងអស់ទាំងនៅជនបទដាច់ស្រយាល ទាំងនៅទីប្រជុំជន។ ផ្អែកតាមការអភិវឌ្ឍដែលវិស័យសុខាភិបាលសម្រេចបានបង្ហាញឲ្យឃើញពីភាពកាន់តែប្រសើរនៃសុខភាពប្រជាជនកម្ពុជា ក្នុងនោះរួមទាំងការគ្របដណ្តប់សេវាថែទាំសុខភាពកុមារ បុរសនិងស្ត្រី អត្រានៃការចាក់ថ្នាំបង្ការជំងឺផ្សេងៗ និងអត្រានៃការធ្លាក់ចុះនៃជំងឺឆ្លងនានា ពិសេសជំងឺអេដស៍។ ក្នុងនោះការផ្តល់សេវាថែទាំទាំងមានគុណភាពចំពោះបុគ្គល ក្រុមគ្រួសារ និងសហគមន៍ ជាបញ្ហាចម្បងដែលក្រសួងសុខាភិបាលបានយកចិត្តទុកដាក់ជាពិសេសអាកប្បកិរិយានិងឥរិយាបទរបស់គិលានុបដ្ឋាកទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់ខ្លួន ដើម្បីធ្វើឲ្យវិស័យសុខាភិបាលកាន់តែមានភាពរីកចម្រើននិងបង្កើនជំនឿទុកចិត្តពីប្រជារាស្ត្រ

ឲ្យកាន់តែប្រសើរឡើងថែមទៀតមកលើប្រព័ន្ធសុខាភិបាល និងធ្វើឲ្យវិស័យនេះរិតតែមានតួនាទីសំខាន់ថែមទៀតក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន (១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាកដែលបានរៀបចំថ្មីនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។



អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លីវ សុខណ្ណា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង ត្រូវបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តំបន់ស្នើសុំបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "សៀមប៉ាង" ខេត្តស្ទឹងត្រែង ត្រូវបានរដ្ឋបាលព្រៃឈើសហការជាមួយអង្គការ Birdlife International ចុះសិក្សាស្រាវជ្រាវចាប់តាំងពីឆ្នាំ២០០៣ កន្លងមក នៅតំបន់ប៉ែកខាងលិចដងទន្លេសេកុង ចាប់ពីទីរួមស្រុកសៀមប៉ាងរហូតដល់អូរកាំជា និងតាមដងទន្លេសេកុងរហូតដល់ក្បែរព្រំប្រទល់កម្ពុជា-ឡាវ ហើយបានរកឃើញនូវវត្តមានសត្វត្រយ៉ងយក្សនិងត្រយ៉ងចង្កំកស ជាប្រភេទជិតផុតពូជបំផុតលើលោក និងមានវត្តមានសត្វព្រៃផ្សេងជាច្រើនទៀតកំពុងរស់នៅ។

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សានីតិកម្ម និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល



ការសិក្សាស្រាវជ្រាវជាលើកដំបូងក្នុងឆ្នាំ២០១៣ បានកត់ត្រាពីវត្តមានសត្វស្លាបសរុបចំនួន ៧៤ប្រភេទ ក្នុងនោះមានត្រយ៉ងយក្សចំនួន ៦ក្បាល និងសត្វត្រយ៉ងចង្កំកស មានចំនួន ២៣ក្បាល ដែលចំនួនច្រើនបែបនេះមិនទាន់បានរកឃើញនៅតាមតំបន់ផ្សេងទៀតនៅកម្ពុជា និងនៅលើពិភពលោកនៅឡើយទេ។ ក្រៅពីនេះក៏បានកត់ត្រាឃើញមានសត្វខ្លាគចំនួន ៣ប្រភេទ និងមានប្រភេទសំខាន់ៗផ្សេងទៀតដែរ ដូចជា អង្គត់ខ្មៅ ក្រៀល រមាំង សុទ្ធតែជាប្រភេទមានដោយកម្រ និងជិតផុតពូជ។

ដោយមើលឃើញពីភាពចាំបាច់ក្នុងការអភិរក្សសត្វព្រៃគ្រប់ប្រភេទនៅកម្ពុជា រដ្ឋបាលព្រៃឈើសហការជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង បានរៀបចំសិក្ខាសាលាលើកទី១ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំផែនការគ្រប់គ្រងនិងអភិរក្សសត្វព្រៃប្រភេទមានដោយកម្រនិងប្រភេទជិតផុតពូជ នៅតាមតំបន់សត្វស្លាបសំខាន់ៗក្នុងភូមិសាស្ត្រស្រុកសៀមប៉ាង ក្នុងអង្គសិក្ខាសាលាបានបង្ហាញពីតំបន់សត្វស្លាបសំខាន់ៗ ដែលនឹងត្រូវធ្វើអភិរក្សពិសេសតំបន់ក្នុងភូមិសាស្ត្រស្រុកសៀមប៉ាងនេះតែម្តង។ អង្គសិក្ខាសាលាទាំងមូលមានការគាំទ្រយ៉ាងពេញទំហឹង(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី១១ ខែធ្នូ ឆ្នាំ២០១៣ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើ របៀបវារៈដូចខាងក្រោម

១- សេចក្តីព្រាងច្បាប់ ស្តីពីផ្លូវថ្នល់។

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖



១- សេចក្តីព្រាងច្បាប់ ស្តីពីផ្លូវថ្នល់៖

-ឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងច្បាប់នេះដោយមានការកែសម្រួលបន្តិចបន្តួច។

-ដើម្បីសម្របតាមកាលៈទេសៈទៅថ្ងៃអនាគត ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស្នើឲ្យរៀបចំការដាក់ពិន័យជាទឹកប្រាក់ក្នុងមាត្រាមួយចំនួនន នៅក្នុងទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់នេះ ដោយកំណត់ក្នុងអនុក្រឹត្យវិញ និងសុំការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់៖

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើឲ្យឯកឧត្តម **អ៊ុន វីរៈជាតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យពិភាក្សាជាមួយ ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់នេះ ដើម្បីដាក់ប្រជុំលើកក្រោយ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបាបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះនៅវេលាម៉ោង ១១:៥៥នាទី។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី២៥ ខែធ្នូ ឆ្នាំ២០១៣ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណា



១-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមសីលធម៌គិលានុបដ្ឋាក។

២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង។ ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

១- សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមសីលធម៌គិលានុបដ្ឋាក៖

-ឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងអនុក្រឹត្យនេះដោយមានការកែសម្រួលមួយចំនួន។

-អង្គប្រជុំបានកែសម្រួលខ្លឹមសារត្រង់ចំណុចអំពីការដាក់វិន័យក្នុងមាត្រា៣៦ថ្មី ពិសេសដោយយោងលើមាត្រា២៨នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា។

២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង៖

-អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងអនុក្រឹត្យនេះ ដើម្បីដាក់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះ នៅវេលាម៉ោង ១០:៣៥នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គ-លេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ មិនទាន់មានតួលេខ

តារាងខាងក្រោម និងក្រាហ្វខាងក្រោម ជាតួលេខពីខែតុលា។

**តារាង១បម្រែបម្រួល.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១-២០១៣**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១៨%, | ១,៧% | ១,0% | ១,0% | ២,៨% | ២,៩% | ៤,0% | ៣,៣% | ៣,៩% | ៤,២% | ៤,២% | ៤,៣% | ២,៩% |
| | ខែមុន | 0៣,% | 0,២% | 0-,១% | 0,៦% | 0,៧% | 0,២% | ១% | 0,៤% | 0,៧% | 0២%, | – 0,១% | 0,១% | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ១,៤% | ១,២% | ១,៦% | ២៦%, | ២៩%, |
| | ខែមុន | ១0,% | 0៤,% | 0៦%, | 0៥%, | -១១%, | 0១%, | 0% | ១,១% | 0,២% | 0-,២% | 0-,២% | 0% | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦៥%, | ៧១%, | ៧១%, | ៦៤%, | ៦៧%, | ៥៣%, | ៥៦%, | ៤៩%, | ៥,៥% |
| | ខែមុន | 0,២% | 0,៧% | 0,៧% | ១,១% | ១៤%, | 0៥%, | 0៦%, | 0២%, | ១0%, | 0១%, | 0,៧%- | 0,៨%- | |

P: តួលេខខែ វិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ២០១៣ ជាតួលេខព្យាករដោយ ក តាមវិធីសាស្រ្ត) .វ.ស.DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន(ឆ្នាំ២០១១ ២០១២ និង២០១៣)




➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | វិច្ឆិកា២០១៣ | តុលា២០១៣ | វិច្ឆិកា២០១២ | *ប្រភេទ* | វិច្ឆិកា២០១៣ | តុលា២០១៣ | វិច្ឆិកា២០១២ |
|---|---|---|---|---|---|---|---|
| រដុល្លា/ | ៣៩៩៥រ១/$ | ៤០៤០រ១/$ | ៣៩៩២រ១/$ | បាតដុល្លារ/ | ៣២,១១បាត១/$ | ៣១,០៨បាត១/$ | ៣០,៦៨បាត១/$ |
| របាត/ | ១២៤របាត១/ | ១៣០របាត១/ | ១៣០របាត១/ | ដុងដុល្លារ/ | ២១០៩០ដុង១/$ | ២១០៨០ដុង១/$ | ២០៨៤០ដុង១/$ |
| រដុង/ | ០,១៨៩រដុង១/ | ០,១៩២រដុង១/ | ០,១៩១រដុង១/ | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

ក្រាហ្វ ២២០១ ចំណូលថវិកាជាតិ ឆ្នាំ .១ — ២០១៣
(ពាន់លានរៀល)




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៥០១,៦ពាន់លានរៀល មធ្យម)ប្រចាំខែ៦៥នៃ %គម្រោង(ក្នុងនោះចំណូលចរន្ត ៥០១ ពាន់លានរៀល មធ្យម)ប្រចាំខែ ៨៩(នៃគម្រោង % និងចំណូលមូលធន ០,៦ពាន់លានរៀល។

- ➢ បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** កើនឡើង ២% ប៉ុន្តែថយចុះ៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណូលចរន្ត កើនឡើង៣% ធៀបនឹងខែមុន ប៉ុន្តែថយចុះ៥% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។
- ➢ ក្នុងចំណូលចរន្ត៖
  - ✓ ចំណូលសារពើពន្ធមានចំនួន ៤១៤,៣ពាន់លានរៀល ថយចុះ ១% ធៀបនឹងខែមុន និងថយចុះ ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៨៦,៧ពាន់លានរៀល កើនឡើង ២៣% ធៀបនឹងខែមុន និងកើនឡើង ៥៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +២១% | +១៤% | ➢ នេសាទ : +៨៣% | (+២០%) |
| ➢ ចំណូលពន្ធដារ : -១៦% | (+១២%) | ➢ រុក្ខាប្រមាញ់ : -៩% | (+១០៣%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ : -១% | (+១៤%) | ➢ សម្បទានរ៉ែ : -៣៩% | (-៥២%) |
| ✧ កាស៊ីណូ : -៤៣% | (-២១%) | ➢ អាកាសចរណ៍ស៊ីវិល : +១១០៥% | (+១០៤៥%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៤៤៦៣% | (+៧៩២%) | ➢ ផលទុននៃសកម្មភាពទេសចរណ៍ : -១០០% | (-១០០%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -៥៧% | (-៥៦%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +១៧% | (+១៧%) |
| | | ➢ អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) : +១៧% | (+៤៩%) (+១៩%) |
| | | ➢ ការត្រួតពិនិត្យគុណភាពផលិតផល : +៤៥២% | |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន៤៥៣ពាន់លានរៀល)*មធ្យមប្រចាំខែ ៥១ %នៃគម្រោង* (ក្នុងនោះ ចំណាយចរន្តមានចំនួន៣៦៤ពាន់លានរៀល )*មធ្យមប្រចាំខែ៧០*និង ( *នៃគម្រោង* %**ចំណាយមូលធន**ចំនួន ៩០ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៨% ប៉ុន្តែថយចុះ ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្ត កើនឡើង ៥% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯចំណាយមូលធន កើនឡើង ១៩% ធៀបនឹងខែមុន និង កើនឡើង ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែវិច្ឆិកា មានអតិរេក ៤៨ ពាន់លានរៀល ស្មើនឹង ១២លានដុល្លារ ស.រ.អា* ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ $M_2$ មានចំនួន ៣០៤១២ពាន់លានរៀល កើនឡើង ៣,៥%ធៀបនឹងខែមុន និងកើនឡើង ១៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃ$M_2$ ធៀបនឹងខែមុន ជាចម្បងបណ្តាលមកពី រូបិយវត្ថុក្រៅធនាគារ កើនឡើង១,៩% និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង៤,១%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៩ ៦%,នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨១៤%,។

ក្រាហ្វ៣២០១៣សមាសធាតុរូបិយវត្ថុខែតុលា ឆ្នាំ .




| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុប ក្នុង និងក្រៅ ធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | ១៦,៩% | ១៦,៨% | ១៨,១% | ១៩% | ១៩,២% | ១៩,៦% | ១៨,២% | |
| ប្រាក់រៀលក្រៅ ធនាគារ | ១៣៧%, | ១៣៧%, | ១៣,៩% | ១៤,០% | ១៣,៣% | ១៣,៤% | ១៤,៣% | ១៤,៥% | ១៤,៧% | ១៤,២% | ១៣,២% | |

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែតុលា២០១៣ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន ៖




➢ ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធមានចំនួន ៣៥២៥លានដុល្លារ កើនឡើង ១៩%, ធៀបនឹងខែមុន និង កើនឡើង ៥,៤ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ៖*** មិនទាន់មានតួលេខ ។

➢ *ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *វិច្ឆិកា ២០១៣* | *តុលា ២០១៣* | *វិច្ឆិកា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ(ពាន់លានរៀល) | — | ២៨៨១១ | ២២០៥២ |
| ក្នុងនោះ ជារៀល | — | — | ៣៨៨ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | — | — | ៣៤៥០ |

➢ ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែវិច្ឆិកា៖

| *ប្រភេទអត្រាការប្រាក់* | *វិច្ឆិកា២០១៣* | *តុលា២០១៣* | *វិច្ឆិកា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | — | — | ៥,៨៨% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | — | — | ១១,៨០% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | — | — | ៤,៤២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | — | — | ១១,៩៨% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែវិច្ឆិកាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម៖**

✓ផលិតផលនេសាទមាន ៥៣,៥ពាន់តោន ថយចុះ ៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម៖**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា (មិនទាន់មានតួលេខ)

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៥៣លានដុល្លារ កើនឡើង ៣% ធៀបនឹងខែមុនប៉ុន្តែថយចុះ ២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន– វិច្ឆិកា២០១៣ | ចំនួន–តុលា២០១៣ | ចំនួន–វិច្ឆិកា២០១២ |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ១៦ | ១២ | ២៣ |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១០៨០ | ១០៦៤ | ៨៧០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២២ | ១៣ | ៣០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២៤ | ១១ | ៤៣ |

➢**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៩២,៧ពាន់ម² ថយចុះ ៣៤ %ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១១៧,៥លានដុល្លារ ថយចុះ ៤៤ %ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម² –វិច្ឆិកា២០១៣ | ពាន់ម² –តុលា២០១៣ | ពាន់ម² –វិច្ឆិកា ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ១៤៧,៨ | ៥២០,៨ | ៨៤,៧ |
| ▪ ឧស្សាហកម្ម | ២០១,៦ | ២៥,៦ | ៤៨,៨ |
| … | | | |
| អនុញ្ញាតសរុប | ៣៩២,៧ | ៥៩៤.៣ | ៣៥០,២ |

✓ ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅឋាន ៣៨% និងឧស្សាហកម្ម ៥១% នៃផ្ទៃក្រឡាសរុប ។

➢**ការងារ៖**

| ប្រភេទ | នាក់ : វិច្ឆិកា២០១៣ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៥៩៥ | +១៤% | -១០% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣១២០ | -១៤% | -៣០% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៧២៤ | -២៩% | -៤៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៣៩៦ | +១៨% | ០ |

➢ **វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ(ថ្មីនិងពង្រីក) .ព.ស.និង គ .ក.វ.៖

| ប្រភេទ | វិច្ឆិកា២០១៣ | តុលា២០១៣ | វិច្ឆិកា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៧៧ | ៨១០ | ៥៤,៨ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ៦៣៧ | ១២៩,៤ |
| វិស័យឧស្សាហកម្ម (ក្នុងរង្វង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៧៧ (២៥) | ១៧៣ (៧) | ១៦៧,៣ (១៥,៧) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ២០៥ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៥ | ២៦ | ២២ |
| បង្កើតការងារ (ពាន់នាក់) | ១៨ | ៣៥ | ៤៦,៥ |

➢ **សេវាកម្ម និងទេសចរណ៍៖**

✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—វិច្ឆិកា២០១៣ | ចំនួន—តុលា២០១៣ | ចំនួន—វិច្ឆិកា២០១២ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៤៣ | ២២៣ | ២១៧ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២ | ៤ | ៤ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៦៦ | ៩០ | ១៧២ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (កំពង់ផែ៥ សរុប) មានចំនួន ៤៣៩,១ពាន់តោន កើនឡើង ២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ៨ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ក្នុងវង់ក្រចក : បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | |
|---|---|
| ▪ កំពង់ផែភ្នំពេញ :២- ២% ៤៦-)% ( | ▪ កំពង់ផែស្រែអំបិល និងកោះកុង : +២៤% )+១៤៧%( |
| ▪ កំពង់ផែកំពង់សោម : +២៧% -)៣(% | ▪ កំពង់ផែឧកញ៉ាម៉ុង : ៦៦%- (៥៣%-) |

➢**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន)ពាន់នាក់( | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១.៧ | +៤៥% | +១៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | | |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | | |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | មិនទាន់មានតួលេខ | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | មិនទាន់មានតួលេខ | | |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែវិច្ឆិកា មានចំនួន ៣៨៣៥ពាន់លានរៀល (៩៥៨,៨លានដុល្លារ) កើនឡើង ៣៥% ធៀបនឹងខែមុន និងកើនឡើង ៤៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១០% | ៤%- | រថយន្តសរុប (រ.ល.ព) | +៥០% | +១៧% |
| ប្រេងម៉ាស៊ូត | +៣១% | +៨% | រថយន្តសរុប (គ្រឿង) | +២៨% | -១៩% |
| ឧស្ម័ន | +៥៤% | +៤៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤៦% | +១៧% |
| អគ្គិសនីនាំចូល | – | – | ម៉ូតូ (គ្រឿង) | | |
| ដែកសំណង់ | +៨៣% | -១៥% | អង្ករ | +៣៩៨% | +៤០៨% |
| ស៊ីម៉ង់ត៍ | +៩០% | +២២% | ផ្លែឈើនិងបន្លែ | +១៩៨% | +២៤៣% |
| គ្រឿងអេឡិចត្រូនិក | | | ជីនិងថ្នាំកសិកម្ម | +៨% | +៩% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | -១០% | +២៤% |

➡ ការនាំចេញខែវិច្ឆិកាឆ្នាំ២០១៣ មានចំនួន ២៦០៥ពាន់លានរៀល ស្មើនឹង៦៥១,២លានដុល្លារ ស.រ.អា ៦៨%) . នៃការនាំចូល (កើនឡើង ២៨% ធៀបនឹងខែមុន និងកើនឡើង ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១១១% | +៨៣៨៣% | ផលិតផលនេសាទ | +១៩% | -៥% |
| វាយនភណ្ឌនិងស្បែកជើង | +២៤% | +២៤% | កៅស៊ូ | +៩៤% | +៣០% |
| អង្ករ | +៤៧% | +៥៤% | | | |

➡ក្នុងខែវិច្ឆិកានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១២៣០ពាន់លានរៀល ស្មើនឹង ៣០៨លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| លរ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលសារពើពន្ធ | −១% | −៥% | — |
| ២ | ពន្ធលើប្រាក់ចំណេញ | −៣៥% | −២០% | — |
| ៣ | ទំនិញឆ្លងកាត់ផែភ្នំពេញ | −២២% | −៤៦% | — |
| ៤ | ការនាំចូលអង្ករ | +៤៩៨% | +៤០៨% | មួយភាគអាចជាការនាំចូលសម្រាប់ជួយដល់ជនរងគ្រោះទឹកជំនន់ និងមួយភាគទៀតអាចជាការនាំចូលដើម្បីនាំចេញ។ |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១)-សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៣នេះ កត្តាមួយចំនួនដែលរួមចំណែកក្នុងសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាគឺ៖

- ការពង្រឹងវិន័យពន្ធ-គយ លើទំនិញនាំចូល
- ជាលទ្ធផល ទំនិញប្រើប្រាស់មួយចំនួនមានការឡើងថ្លៃ
- និង មានការកកស្ទះទំនិញនាំចូលមួយចំនួននៅច្រកព្រំដែន

២)-ក្នុងឆ្នាំ ២០១៥ ចំណូលពន្ធគយនឹងថយចុះយ៉ាងខ្លាំង ដោយសារការថយចុះអត្រាពន្ធគយ ដូច្នេះប្រព័ន្ធពន្ធដារកម្ពុជា គួរបានធ្វើកំណែទម្រង់ជាបណ្តើរៗ ពាក់ព័ន្ធនឹងតម្លាភាព នីតិវិធី និងប្រសិទ្ធភាពប្រមូលពន្ធ។

៣)-ដើម្បីប៉ះប៉ូវដល់ការថយចុះនៃចំណូលពន្ធគយ មូលដ្ឋានពន្ធដារពិសេសមួយចំនួននឹងត្រូវបង្កើតឡើង

៤)-បច្ចុប្បន្ន ផលិតកម្មអគ្គិសនីមានចំនួនតិចជាងការនាំចូល ចំណែកឯការប្រើប្រាស់កើនឡើង ២០% ជាមធ្យមប្រចាំឆ្នាំ។ ប្រទេសវៀតណាមមានផែនការតម្លើងថ្លៃអគ្គិសនីនាំចូលមកកម្ពុជា។

៥)-ដីដែលនៅជុំវិញតំបន់មរតកវប្បធម៌មួយចំនួន ដូចជាប្រាសាទបុរាណ ត្រូវបានប្រជាពលរដ្ឋរស់នៅ និងស្នើសុំកម្មសិទ្ធិរស់នៅ ដែលតាមបទដ្ឋានច្បាប់ ត្រូវរក្សាចម្ងាយយ៉ាងតិច ៣០០ម៉ែត្រ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែធ្នូ ឆ្នាំ២០១៣**

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៦/១២/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស លើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យា នៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៨/១២/១៣ ម៉ោង ១៥:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីដុតភ្លើងបូជាសព ឯកឧត្តម **យឹម បូ** នៅវត្តក្រពើហារ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។ |
| ៣ | ០៩/១២/១៣ ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ជាប សត្ថារតន៍** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៩/១២/១៣ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១០/១២/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងទិវាជនពិការកម្ពុជាលើកទី១៥ និងទិវាជនពិការអន្តរជាតិលើក ទី៣១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាល មហោស្រពកោះពេជ្រ។ |
| ៦ | ១០/១២/១៣ ម៉ោង ១៧:៣០នាទី | ចូលរួមក្នុងឱកាសប្រារព្ធពិធីទិវាសិទ្ធិមនុស្សអន្តរជាតិ នៅ European Union Delegation។ |
| ៧ | ១១/១២/១៣ ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១២/១២/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យ នៅជាប់របង ជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងប្រកាសការបង្កើតក្រុមការងារបច្ចេកទេស ដើម្បីកំណត់តំបន់គ្រប់គ្រងសន្តិសុខសុវត្ថិភាពជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងកំណត់ពេលវេលាចុះវាស់វែង នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៣/១២/១៣ ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យលើការលើកលែងពន្ធអាករលើតម្លៃបន្ថែម VAT១០% សម្រាប់ការងារស្តារនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ ពីស្តុបសណ្ឋាគារសុខាអង្គរដល់អាកាសយានដ្ឋានយោធាខេត្តសៀមរាប ដែលអនុវត្តគម្រោង ដោយកងវិស្វកម្មសម្តេចតេជោ **ហ៊ុន សែន** ខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៣/១២/១៣ ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិន ជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យលើសៀវភៅបន្ទុក BoQ សម្រាប់សាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | ១៦/១២/១៣<br>ម៉ោង ១០:០០នាទី | ជួបប្រជុំពិភាក្សាការងារដែលពាក់ព័ន្ធទៅនឹងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាមួយឯកឧត្តម **ផេង សុវិជ្ជាគោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៧/១២/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២២ ប្រចាំឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ១៣ | ១៧/១២/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៤ | ១៨/១២/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមជាអធិបតី ក្នុងសិក្ខាសាលាស្តីពីការយល់ដឹងអំពីគម្រោង និងវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (គម្រោង វ.ផ.ល) ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន នៅសណ្ឋាគារភ្នំពេញ។ |
| ១៥ | ១៨/១២/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យការងារសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងការស្ថាបនាពង្រីកស្ថានីយអ្នកដំណើរនៅអាកាស យានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៩/១២/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៣/១២/១៣<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ១៨ | ២៤/១២/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹង ត្រែង។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២៥/១២/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាល ផ្តល់អនុសាសន៍ណែនាំ និងពិធីផ្តល់ពានរង្វាន់លើកទឹកចិត្ត ជូនដល់កីឡាករ កីឡាការនីជ័យលាភីជើងឯកពិភពលោកលើកទី១៤ និងជើងឯកទ្វីបអាស៊ីលើកទី១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ២០ | ២៧/១២/១៣<br>ម៉ោង ១៦:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីប្រកាសចូលកាន់តំណែងរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងពិធីផ្ទេរអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជូនក្រសួងរ៉ែ និងថាមពល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សិក្ខាសាលាស្ដីពីការយល់ដឹងជាសាធារណៈលើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ( ADB Grant No. 0224 )

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) រៀបចំសិក្ខាសាលាស្ដីពីការយល់ដឹងជាសាធារណៈ អំពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) នៅសណ្ឋាគារភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយសិក្ខាកាមចូលរួមក្នុងអង្គសិក្ខាសាលានាថ្ងៃនេះមានថ្នាក់ដឹកនាំនិងមន្ត្រីជំនាញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីគម្រោង RIA សរុបទាំងអស់ប្រមាណ ២០០រូប។ សិក្ខាសាលាថ្ងៃនេះ គឺជាការបន្តកម្មវិធីផ្សព្វផ្សាយជាសាធារណៈស្ដីពីវិធីសាស្ត្រ RIA និងការអនុវត្ត RIA ដល់ក្រសួង-ស្ថាប័ន ក្រុមប្រឹក្សានិងអាជ្ញាធរពាក់ព័ន្ធ រាជបណ្ឌិត្យសភាកម្ពុជា សាលាភូមិន្ទរដ្ឋបាល គ្រឹះស្ថានឧត្តមសិក្សាជាន់ខ្ពស់ ព្រមទាំងវិស័យឯកជន-អ្នកធុរកិច្ច និងសង្គមស៊ីវិល ដែលបានអនុវត្តកន្លងមកជាច្រើន។ គម្រោងRIAនេះ ទទួលហិរញ្ញប្បទានឥតសំណងពី ADB លេខ ០២២៤ ដែលជាផ្នែកមួយនៃកម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច "Promoting Economic Diversification" (PED) របស់ ADB។




វាគ្មិននៅក្នុងព្រឹត្តិការណ៍នាថ្ងៃនេះមាន ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជានាយកគម្រោង RIA ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអ្នកគ្រប់គ្រងគម្រោងRIA លោក Sabesh ប្រធានក្រុមទីប្រឹក្សារបស់ក្រុមហ៊ុនPOHL និងឯកឧត្តមបណ្ឌិត **ឈុន វឌ្ឍនៈ** អគ្គលេខាធិការគណៈកម្មការជាតិអភិវឌ្ឍន៍បៃតង និងជាប្រធានក្រុមការងារអនុវត្តគម្រោងRIA នៅក្រសួងបរិស្ថាន។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត គឺជាការវិភាគមានលក្ខណៈជាប្រព័ន្ធលើសំណើបញ្ញត្តិកម្មជាឧបករណ៍ និងជាវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំសំណើបញ្ញត្តិកម្មឲ្យប្រសើរ

ឡើងនិងមានប្រសិទ្ធភាពខ្ពស់ ដោយផ្តល់ព័ត៌មានពីបន្ទុកចំណាយនិងផលចំណេញនៃសំណើបញ្ញត្តិកម្មឲ្យបានច្បាស់លាស់ជូនថ្នាក់ដឹកនាំសម្រេច ដើម្បីលើកកម្ពស់គោលនយោបាយប្រកួតប្រជែង ព្រមទាំងអភិបាលកិច្ចល្អ។ នៅប្រទេសកម្ពុជា ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត អាស្រ័យលើការវិភាគដោយផ្អែកលើសុភវិនិច្ឆ័យ និងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។



គម្រោងRIA បាននិងកំពុងដំណើរការបានល្អគួរឲ្យកត់សម្គាល់ ចាប់តាំងពីពេលចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១១មក។ គម្រោងRIA មានទីភ្នាក់ងារប្រតិបត្តិគម្រោង(ហៅថាEA) ស្ថិតនៅក្រោម ECOSOCC ដែលជាអង្គភាពចំណុះទីស្តីការណៈរដ្ឋមន្ត្រី និងបច្ចុប្បន្នមានក្រសួងចំនួន៤ចូលរួមជាទីភ្នាក់ងារអនុវត្តគម្រោង (ហៅថាIA) រួមមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងក្រសួងទេសចរណ៍។ ក្រោយពបានទទួលការបណ្តុះបណ្តាល ដោយអ្នកជំនាញរបស់ក្រុមទីប្រឹក្សានៃក្រុមហ៊ុនPOHL និងការសិក្សាដកបទពិសោធន៍ការអនុវត្តRIAនៅប្រទេសអភិវឌ្ឍន៍ ដូចជាប្រទេសអូស្រ្តាលី និងប្រទេសអង់គ្លេស ក្រសួងទីភ្នាក់ងារអនុវត្តគម្រោងសម្រេចបាននូវរបាយការវាយតម្លៃបឋម ច្រើនបង្គួរនិងមានគុណភាពដែលធនាគារអភិវឌ្ឍន៍អាស៊ីបានវាយតម្លៃខ្ពស់ថា ការអនុវត្តគម្រោងRIAនៅកម្ពុជាសម្រេចបានលទ្ធផលល្អប្រសើរ នៅក្នុងរបាយការណ៍វាយតម្លៃសម្រាប់ពាក់កណ្តាលដំណាក់កាលនៃការអនុវត្តគម្រោង ដោយការខំប្រឹងប្រែងរបស់មន្ត្រីគម្រោងRIA ទាំងនៅ ECOSOCC ទាំងនៅក្រសួងទីភ្នាក់ងារអនុវត្តគម្រោងទាំងអស់។

នៅដើមឆ្នាំ២០១៤ រាជរដ្ឋាភិបាល នឹងបញ្ចូលក្រសួងចំនួន៣ បន្ថែមទៀត គឺ ១-ក្រសួងអប់រំ យុវជន និងកីឡា ២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង៣-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យចូលរួមជាទីភ្នាក់ងារអនុវត្តគម្រោងRIA ហើយបើវាយតម្លៃឃើញថាការអនុវត្តគម្រោងRIA ក្នុងដំណាក់កាលសាកល្បងនេះបានជោគជ័យ នឹងសម្រេចឲ្យអនុវត្តនូវវិធីសាស្ត្រRIA សម្រាប់វាយតម្លៃលើផលប៉ះពាល់នៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលមានផលប៉ះពាល់ដល់ធុរកិច្ច និងវិនិយោគនៅគ្រប់ក្រសួងស្ថាប័នរដ្ឋទាំងអស់។

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានទទួលស្វាគមន៍សិស្សមន្ត្រីក្រមការជំនាន់ទី៥ នៃសាលាភូមិន្ទរដ្ឋបាល

ឯកឧត្តម **ថាន់ តិរុណា** អគ្គលេខាធិការ ក.ស.វ. បានចាត់តាំង ឯកឧត្តម **ហ៊ី គឹមហឿង** អគ្គលេខាធិការរង ធ្វើជាប្រធានកម្មសិក្សាសម្រាប់ជួយសម្របសម្រួល និងណែនាំការងារធ្វើកម្មសិក្សារបស់សិស្ស មន្ត្រីក្រមការទាំង០៣រូបគឺ លោក **សុខ ពិសិដ្ឋ** លោក **បេ ប៉េងអ៊ី** និងលោក **ឃាង ម៉េងឈុន** ចុះមកធ្វើកម្មសិក្សានៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងរយៈពេល ០២ខែកន្លះ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

បន្ទាប់មក ឯកឧត្តម **ហ៊ី គឹមហឿង** បានណែនាំពីរចនាសម្ព័ន្ធ ក.ស.វ. និងការងាររដ្ឋបាលនៅអគ្គលេខាធិការដ្ឋាន ក.ស.វ.។ បន្ថែមពីនេះ បានបញ្ជូនសិស្សទាំង០៣រូប ឲ្យចុះធ្វើការងារអនុវត្តផ្ទាល់ ដូចជាចូលរួមប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចូលរួមប្រជុំជំនាញបច្ចេកទេសតាមក្រុមនីមួយៗ ។ល។ ក្រោយពីបញ្ចប់ការស្វែងយល់ពីដំណើរការរបស់អគ្គលេខាធិការដ្ឋាន ក.ស.វ. ឯកឧត្តម **ថាន់ តិរុណា** ក៏បានណែនាំឲ្យចុះស្វែងយល់ពីគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA)។ គម្រោងនេះបានទទួលហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍអាស៊ី(ADB)។ គម្រោងនេះនឹងអាចកាត់បន្ថយចំណាយកាតព្វកិច្ច និងលើកកម្ពស់បរិស្ថានប្រកួតប្រជែង ដែលធ្វើឲ្យធុរកិច្ចកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ លើសពីនេះទៀត គម្រោងនេះនឹងជួយកាត់បន្ថយភាពជាន់គ្នានិងគ្មានសង្គតិភាពក្នុងចំណោមលិខិតបទដ្ឋានគតិយុត្ត។ គម្រោង RIA នេះ មានទីភ្នាក់ងារប្រតិបត្តិគម្រោង ហៅថា(EA) ស្ថិតនៅ





ECOSOCC ដែលជាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងមានក្រសួងពាក់ព័ន្ធចំនួន០៤ ចូលរួមជាទីភ្នាក់ងារអនុវត្តគម្រោង ហៅថា(IA) រួមមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍ ។

នៅថ្ងៃបញ្ចប់កម្មសិក្សា ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ជាប្រធាន ឯកឧត្តម **ឃឹម ណុលសន** និងឯកឧត្តម **ឱុយ ឆៅ** អនុប្រធាន ព្រមទាំងឯកឧត្តម **ម៉ាន់ តិរុណា** អគ្គលេខាធិការ បានជួបសំណេះសំណាល ចែករំលែកបទពិសោធ និងផ្តល់អនុសាសន៍ដល់សិស្សកម្មសិក្សាទាំង០៣រូប ត្រូវយកចំណេះដឹងដែលទទួលបានពីការចុះធ្វើកម្មសិក្សានៅអគ្គលេខាធិការដ្ឋាន ក.ស.វ. ទៅប្រើប្រាស់ឲ្យមានប្រយោជន៍ក្នុងការសិក្សា និងក្នុងសង្គម។ ម៉្យាងវិញទៀត ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** បានណែនាំដល់សិស្សកម្មសិក្សាទាំង ៣រូប នេះថា ក្មួយៗនឹងក្លាយទៅជាមន្ត្រី ដូច្នេះក្មួយៗត្រូវបន្តខិតខំរៀនសូត្រ ដើម្បីយកចំណេះដឹងមកបម្រើប្រជាជន និងជួយកសាង និងអភិវឌ្ឍប្រទេសជាតិ។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានរំលឹកអំពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងក្នុងពិធីប្រគល់សញ្ញាបត្រជូនសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ស្ថិរភាពសង្គម សិស្សមន្ត្រីក្រមការជំនាន់សមធម៌សង្គម និងប្រគល់វិញ្ញាបនបត្រដល់កម្មសិក្សាការីឆ្នាំ២០១១-២០១២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៣ របស់សាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣ ថា "ដែលហៅថាមន្ត្រីរបស់យើង ត្រូវចាំឲ្យបានថា យើងមិនមែនជាអ្នកត្រួតត្រា ហើយក៏មិនមែនជាម្ចាស់របស់ប្រជាជន ផ្ទុយទៅវិញយើងជាអ្នកបម្រើ និងជាអ្នកផ្តល់សេវាជូនប្រជាជន"។

បន្ទាប់មក **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រគល់ជូននៅវិញ្ញាបនបត្របញ្ជាក់ពីការចុះធ្វើកម្មសិក្សាប្រកបដោយជោគជ័យជូនសិស្សកម្មសិក្សាទាំង០៣រូប និងបានជួយឧបត្ថម្ភថវិកាមួយចំនួន និងបានថតរូបទុកជាអនុស្សាវរីយ៍។



# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅៈ | ឯកឧត្តម គីម សយសាម៉ាឡៃន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយកៈ | ឯកឧត្តម ហ៊ាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទៈ | ឯកឧត្តម អេង វត្តមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ចៈ | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយៈ | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួលៈ | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូបៈ | លោក មុត ភក្តដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០
ទូរសារលេខៈ ០២៣ ២១១ ៩៤៣
E-mail: veasna@live.in